២-ក្រុមហ៊ុនថៃប៊ុនរ៉ុង ដែលមានព្រៃសម្បទានស្ថិតនៅខេត្តក្រចេះ និងមណ្ឌលគិរី មានផ្ទៃដី សរុប ចំនួន ៤១៦.៧០០ ហិកតា ហើយបានផុតសុពលភាពនៃកិច្ចព្រមព្រៀងនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ។

៣-ក្រុមហ៊ុនប៉ាស៊ីហ្វិកព្រាយវូដដែលមានព្រៃសម្បទានស្ថិតនៅខេត្តស្ទឹងត្រែង មានផ្ទៃដីសរុប ចំនួន ១៤.៥៤៧ ហិកតា ហើយបានផុតសុពលភាព ១ឆ្នាំ ។

ប្រការ ២ : ការលុបចោលកិច្ចព្រមព្រៀងព្រៃសម្បទានរបស់ក្រុមហ៊ុនទាំង ០៣ ដែលមានចែងក្នុងប្រការ១ ខាងលើរាជរដ្ឋាភិបាលមិនមានការទូទាត់សងសំណងណាមួយឡើយ ។

ប្រការ ៣ : ព្រៃសម្បទានដែលដកហូតពីក្រុមហ៊ុនទាំង៣ ខាងលើនេះ ត្រូវរក្សាទុកជាតំបន់ព្រៃបម្រុងទុក ។

ប្រការ ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន អភិបាលខេត្ត - ក្រុង ដែលពាក់ព័ន្ធ និង ក្រុមហ៊ុនទាំង ៣ ដែលមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ ,ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩

## សេចក្តីសម្រេចលេខ ០៥ សសរ
## ស្តីពីការបង្កើតមជ្ឈមណ្ឌលអប់រំបច្ចេកវិទ្យា
## នៅរោងជាងស្វ័យយានកម្ពុជា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស ។
- បានឃើញអនុក្រឹត្យលេខ ១៥ អន.ក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- តាមសំណើរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- ដោយមានការឯកភាពពីក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងផែនការ

**សំរេច**

ប្រការ ១ : ត្រូវបានបង្កើតគ្រឹះស្ថានមធ្យមសិក្សាឯកទេសផ្លូវដែកមួយ នៅរាជអយស្ម័យយានកម្ពុជា ដែលមានឈ្មោះថា មជ្ឈមណ្ឌលអប់រំបច្ចេកវិទ្យារាជអយស្ម័យយានកម្ពុជា " ម.អ.ប " ។ គ្រឹះស្ថាននេះត្រូវស្ថិតនៅក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតនៅក្រោមការត្រួតពិនិត្យបច្ចេកទេស និងគរុកោសល្យពីក្រសួងអប់រំ យុវជននិងកីឡា ។

ប្រការ ២ : មជ្ឈមណ្ឌលអប់រំបច្ចេកវិទ្យារាជអយស្ម័យយានកម្ពុជា មានភារកិច្ច ៖

- បណ្តុះបណ្តាល កម្មករ បុគ្គលិក ក្នុងផ្នែកដែលមិនទាន់មានជំនាញបច្ចេកទេស ដោយបណ្តុះបណ្តាល អ្នកបច្ចេកទេសថ្នាក់មធ្យម ថ្នាក់កម្មករជំនាញគ្រប់ផ្នែក អំពីជំនាញអយស្ម័យយាន ។
- ជ្រើសរើសនិងបណ្តុះបណ្តាល សិស្ស និស្សិត ដែលបានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬ រៀនចប់ថ្នាក់ទី១២ ចំណេះទូទៅ អំពីជំនាញទូទៅ និងជំនាញអយស្ម័យយាន ។
- ចាត់តាំងថ្នាក់ក្រឹត្យការ ដើម្បីបំពាក់បំប៉នចំណេះដឹង ចំណេះធ្វើបន្ថែមបច្ចេកវិទ្យាអយស្ម័យយានគ្រប់ផ្នែកក្នុងរាជអយស្ម័យយានកម្ពុជា សំរាប់ថ្នាក់មធ្យម ថ្នាក់កម្មករជំនាញ ថ្នាក់ទេព ដែលបានបំពេញការងារហើយចង់ពង្រីកមុខជំនាញរបស់ខ្លួន ។
- អនុវត្តជាក់ស្តែង និងធ្វើតេស្តពិសោធន៍ ដែលជាផ្នែកមួយយ៉ាងសំខាន់ត្រូវស្រាវជ្រាវរកឃើញ ដើម្បីលើកស្ទួយចំណេះដឹងដល់គ្រូបង្រៀន សិស្សនិងគុណភាពបណ្តុះបណ្តាល ។
- ចាត់តាំងការងារពិសោធន៍គ្រប់មុខជំនាញអយស្ម័យយាននិងអនុវត្តជាក់ស្តែងនៅតាមបណ្តា រោងជាងផលិតកម្ម រោងជាងជួសជុល របណ្តាក្បាលរថភ្លើងជួសជុលផ្លូវដែក និងតាមស្ថានីយ រថភ្លើងនានា ដែលកំពុងធ្វើអាជីវកម្ម ។
- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់មជ្ឈមណ្ឌលអប់រំបច្ចេកវិទ្យារាជអយស្ម័យយានកម្ពុជាជូនក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងអប់រំ យុវជននិងកីឡា។

ប្រការ ៣ : នាយកមជ្ឈមណ្ឌលអប់រំបច្ចេកវិទ្យារាជអយស្ម័យយានកម្ពុជា មានបុព្វសិទ្ធិស្មើ នឹងអនុប្រធាននាយកដ្ឋានរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងមាននាយករងមួយរូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ។

ប្រការ ៤ : ជំពោះមុខ មជ្ឈមណ្ឌលអប់រំបច្ចេកវិទ្យារាជាយស្ម័យយានកម្ពុជា នឹងបើកបង្រៀនជំនាញបច្ចេកទេស ដូចតទៅ ៖

១-មុខជំនាញសំណង់ ជួសជុលថែទាំផ្លូវដែក ស្ពាន អាគារ

២-មុខជំនាញមេកានិក ជួសជុលថែទាំក្បាលម៉ាស៊ីន និងទូររថភ្លើង

៣-មុខជំនាញអាជីវកម្មដឹកជញ្ជូនតាមផ្លូវដែក

លើសពីនេះ មជ្ឈមណ្ឌលអប់រំបច្ចេកវិទ្យារាជាយស្ម័យយានកម្ពុជា នឹងអាចបើកបង្រៀនមុខជំនាញផ្សេងៗទៀតតាមការជាក់ស្តែង ក្រោយពីមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងផែនការ ។

ប្រការ ៥ ៖ មជ្ឈមណ្ឌលអប់រំបច្ចេកវិទ្យារាជាយស្ម័យយានកម្ពុជាកាន់កាប់ និងប្រើប្រាស់គណនេយ្យ តាមប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវបានឧបត្ថម្ភពីថវិកាជាតិ សំរាប់បណ្តុះបណ្តាល និងមានខ្ទង់គណនេយ្យដោយឡែក ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងផែនការ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុក អនុវត្តសេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## III- ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩

### ប្រកាសលេខ ៥៦ ឧក.ប្រក

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា